# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**លេខ** ០៦ សណ.ន.......

# សេចក្តីណែនាំ
## ស្តីពី
## ការដាក់ឱ្យអនុវត្តនីតិវិធីនិងទម្រង់បែបបទនៃការគ្រប់គ្រងទីតាំងផលិត និងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍

ដើម្បីទទួលបាននូវប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់សម្រាប់ការអនុវត្តអនុក្រឹត្យលេខ១៨ អនក្រ.បក. ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ស្របតាមប្រកាសរួមលេខ៦៥៧ សហវ.ប្រក. ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងដើម្បីធានាបាននូវការប្រមូលកម្រៃសេវាសាធារណៈស្របតាមលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈសូមធ្វើការណែនាំដូចខាងក្រោម៖

១. គ្រប់សកម្មភាពដែលទាក់ទងនឹងការផលិតនិងការលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ ការរចនា ការច្នៃប្រឌិតដើម្បីឱ្យកើតចេញជាផលិតផលវត្ថុសិល្បៈដើម្បីធ្វើអាជីវកម្ម ត្រូវមានទីតាំងជាក់លាក់។

២. បុគ្គលដែលប្រកបអាជីវកម្មទាក់ទងនឹងការផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ ត្រូវបំពេញបែបបទស្នើសុំការអនុញ្ញាតមកការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមគំរូពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

៣. បុគ្គលិកជួរក្រោយការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះពិនិត្យដល់ទីតាំងអាជីវកម្មដើម្បីផ្តល់យោបល់បច្ចេកទេសជូនប្រធានការិយាល័យច្រកចេញចូលតែមួយ មុននឹងដាក់សំណុំបែបបទស្នើសុំការអនុញ្ញាតធ្វើអាជីវកម្មជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យសម្រេច។

៤. រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានសិទ្ធិចេញបណ្ណអនុញ្ញាតអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍តាមរយៈការិយាល័យច្រកចេញចូលតែមួយ។

៥. ម្ចាស់អាជីវកម្មត្រូវបង្ហាញបណ្ណអនុញ្ញាតអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ ជាសាធារណៈដើម្បីឱ្យបុគ្គលិកជួរក្រោយការិយាល័យច្រកចេញចូលតែមួយ ងាយស្រួលអនុវត្តការងារនិងត្រួតពិនិត្យ។

៦. បុគ្គលិកជួរក្រោយការិយាល័យច្រកចេញចូលតែមួយ ត្រូវជំរុញដល់ម្ចាស់អាជីវកម្មឱ្យមកទទួលសេវាសាធារណៈជារៀងរាល់ឆ្នាំ តាមរយៈយន្តការច្រកចេញចូលតែមួយ។ ករណីម្ចាស់អាជីវកម្មមិនមកទទួលសេវាសាធារណៈ បន្ទាប់ពីបានការឯកភាពពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ បុគ្គលិកជួរក្រោយការិយាល័យច្រកចេញចូលតែមួយ ត្រូវដាក់លិខិតអញ្ជើញជាផ្លូវការដោយទុករយៈពេល១៥ថ្ងៃ។ គំរូលិខិតអញ្ជើញមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

៧. ករណីម្ចាស់អាជីវកម្មមិនមកទទួលសេវាសាធារណៈតាមរយៈលិខិតអញ្ជើញ បុគ្គលិកជួរក្រោយការិយាល័យច្រកចេញចូលតែមួយ ត្រូវស្នើសុំការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីផ្អាកអាជីវកម្មបណ្តោះអាសន្ន។ គំរូលិខិតផ្អាកអាជីវកម្មបណ្តោះអាសន្ន មានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

៨. កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពបណ្ណអនុញ្ញាតអាជីវកម្មលើទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ ត្រូវអនុវត្តតាមប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

៩. រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ជាទៀងទាត់អំពីការចេញបណ្ណអនុញ្ញាតសម្រាប់ការផ្តល់សេវាសាធារណៈក្នុងវិស័យវប្បធម៌និងវិចិត្រសិល្បៈមករដ្ឋបាលរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយចម្លងជូនក្រសួងមហាផ្ទៃ និង មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត តាមគោលការណ៍កំណត់។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.ចន្ទ..១៣កើត..........ខែភទ្របទ.... ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.៣១.... ខែ.សីហា...... ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

# ពាក្យស្នើសុំ
# បណ្ណអនុញ្ញាតអាជីវកម្ម
# លើទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំ
# បណ្ណអនុញ្ញាតអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍

ខ្ញុំបាទ-នាងខ្ញុំ ឈ្មោះ…………………………………… អក្សរឡាតាំង ………………………………………… ភេទ………… ថ្ងៃខែឆ្នាំកំណើត………………………… សញ្ជាតិ ……………… អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ……… ផ្លូវ…………ភូមិ ………………… ឃុំ/សង្កាត់ ………………………ក្រុង/ស្រុក/ខណ្ឌ ………………………………… រាជធានី/ខេត្ត ………………… អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ ………………………………… លេខទូរសព្ទទំនាក់ទំនង ……………………………………… ជាម្ចាស់/តំណាង……………………………………………។

**សូមគោរពជូន**
**លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**
……………………………………………………………………………

**កម្មវត្ថុ** ៖ សំណើសុំផ្តល់បណ្ណអនុញ្ញាតអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **លោក លោកស្រីអភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាជ្រាបថា៖ ខ្ញុំបាទ-នាងខ្ញុំសូមស្នើបណ្ណអនុញ្ញាតអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ដែលមាន៖

- នាមករណ៍ជាភាសាខ្មែរ ……………………………… ជាអក្សរឡាតាំង ………………………………
- អាសយដ្ឋាន ………………………………………………………………………………………
- ទូរសព្ទ ……………………………………… អ៊ីម៉ែល ……………………………………………………។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **លោក លោកស្រីអភិបាល** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

*សូមជូនភ្ជាប់មកជាមួយ៖*

| | |
|---|---|
| ១- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកដាក់ពាក្យស្នើសុំ (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ២- វិញ្ញាបនបត្រ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ៣- រូបថតបច្ចុប្បន្នទំហំ៤x៦ | ៣សន្លឹក |
| ៤- កិច្ចសន្យា | ១ច្បាប់ |
| ៥- ប្លង់គំនូសបង្ហាញទីតាំង | ១ច្បាប់ |

សូម **លោក លោកស្រីអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ………………………… ខែ………… ឆ្នាំ……………………… ព.ស. …………

ថ្ងៃទី………… ខែ……………… ឆ្នាំ…………

ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំ (បន្ត)
# បណ្ណអនុញ្ញាតអាជីវកម្មទីតាំងផលិតលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍

ខ្ញុំបាទ-នាងខ្ញុំ ឈ្មោះ.................................... អក្សរឡាតាំង .............................................. ភេទ............ ថ្ងៃខែឆ្នាំកំណើត.............................. សញ្ជាតិ ................. អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ........ ផ្លូវ............ភូមិ ..................... ឃុំ/សង្កាត់ ..........................ក្រុង/ស្រុក/ខណ្ឌ ..................................... រាជធានី/ខេត្ត ..................... អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ ................................... លេខទូរសព្ទ ទំនាក់ទំនង ........................................ ជាម្ចាស់/តំណាង.............................................។

## សូមគោរពជូន
## លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ
.........................................................................................

**កម្មវត្ថុ ៖** សំណើសុំផ្តល់បណ្ណអនុញ្ញាតបន្តអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **លោក លោកស្រី អភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាជ្រាបថា៖ ខ្ញុំបាទ-នាងខ្ញុំសូមស្នើបណ្ណអនុញ្ញាតបន្តអាជីវកម្មទីតាំងផលិតនិង លក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ដែលមាន៖

- នាមករណ៍ជាភាសាខ្មែរ ........................................ ជាអក្សរឡាតាំង .......................................
- អាសយដ្ឋាន ..........................................................................................................
- ទូរសព្ទ ............................................ អ៊ីម៉ែល ........................................................។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **លោក លោកស្រីអភិបាល** មេត្តាពិនិត្យនិងសម្រេចដោយ សេចក្តីអនុគ្រោះ។

*សូមជូនភ្ជាប់មកជាមួយ៖*

| | |
|---|---|
| ១- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកដាក់ពាក្យស្នើសុំ (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ២- វិញ្ញាបនបត្រ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ៣- រូបថតបច្ចុប្បន្នទំហំ៤x៦ | ៣សន្លឹក |
| ៤- កិច្ចសន្យា | ១ច្បាប់ |
| ៥- ប្លង់គំនូសបង្ហាញទីតាំង | ១ច្បាប់ |

សូម **លោក លោកស្រីអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ........................... ខែ.............. ឆ្នាំ...........................ព.ស. ...........

ថ្ងៃទី.............ខែ..................... ឆ្នាំ.............

ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
# ផ្តល់បណ្ណអនុញ្ញាត
# អាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ....................................... ជាអក្សរឡាតាំង ....................................... ភេទ ............ ថ្ងៃខែឆ្នាំកំណើត ...................... សញ្ជាតិ .............. តួនាទី (ម្ចាស់ ឬ អ្នកគ្រប់គ្រងអាជីវកម្ម) ............................. ប្រកបអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ឈ្មោះ (ខ្មែរនិងឡាតាំង) ........... ........................................ ទូរសព្ទ ................................ អ៊ីម៉ែល ឬ វេបសាយ .......................។

## សូមធ្វើកិច្ចសន្យាដូចខាងក្រោម៖

១- ជានាគោរពគោលការណ៍និងបទប្បញ្ញត្តិច្បាប់របស់រដ្ឋ
២- ជានាគោរពគោលការណ៍ណែនាំរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង រដ្ឋបាលក្រុង ស្រុក ខណ្ឌ
៣- ជានាគោរពនូវរាល់ក្បួនខ្នាត ក្បាច់ចម្លាក់ ទម្រង់ និងសិល្បៈរបស់ជាតិ
៤- ជានាសហការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់
៥- ជានាមិនធ្វើអាជីវកម្មវត្ថុបុរាណ ដោយដាក់តាំងលាយឡំជាមួយផលិតផលថ្មី
៦- ករណីទីតាំងអាជីវកម្មខ្ញុំមានតាំងលក់សម្ភារៈ បរិក្ខារនានាដែលត្រូវស្នើសុំលិខិតអនុញ្ញាត ឬ បណ្ណអនុញ្ញាតក្នុងវិស័យជំនាញដទៃទៀត ខ្ញុំនឹងអនុវត្តតាមលិខិតបទដ្ឋានជាធរមានក្នុងវិស័យនោះ
៧- អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិផ្អាកជាបណ្តោះអាសន្ន ឬ បញ្ឈប់ជាផ្លូវការរាល់ការធ្វើអាជីវកម្មណាដែលពិនិត្យឃើញថាមិនបានគោរពតាមកិច្ចសន្យាខាងលើ។

ករណីមិនអនុវត្តកិច្ចសន្យានេះ ខ្ញុំបាទ-នាងខ្ញុំសូមទទួលទោសតាមច្បាប់របស់រដ្ឋដែលបានកំណត់ជាធរមាន។

ថ្ងៃ.......................... ខែ.............. ឆ្នាំ............................ព.ស. ...........

ថ្ងៃទី.............ខែ.................... ឆ្នាំ..............

**ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតបញ្ជាក់ទីតាំង

របស់ឈ្មោះ ............................................ ឈ្មោះអាជីវកម្ម ............................................

អាសយដ្ឋាន ផ្ទះលេខ ............ ផ្លូវ ................ ភូមិ ................ ឃុំ/សង្កាត់ ...................... ក្រុង/ស្រុក/ខណ្ឌ

............................. រាជធានី/ខេត្ត ............................. ដូចបានបង្ហាញនៅក្នុងគំនូសបំព្រួញខាងក្រោម៖

<u>គំនូសបំព្រួញបង្ហាញទីតាំង</u>

ថ្ងៃ........................... ខែ.............. ឆ្នាំ..........................ព.ស. ............

ថ្ងៃទី............. ខែ.................. ឆ្នាំ..............

**ស្នាមមេដៃស្ដាំ និង ឈ្មោះអ្នកស្នើសុំ**

លេខ: ......................

បានឃើញនិងបញ្ជាក់

គំនូសបំព្រួញទីតាំងនេះពិតជាត្រឹមត្រូវប្រាកដមែន។

ថ្ងៃទី............. ខែ.................. ឆ្នាំ..............

ហត្ថលេខាមេឃុំ/ចៅសង្កាត់

រដ្ឋបាល......................................

លេខ : ..................................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# បណ្ណអនុញ្ញាត

# អាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍

យោង ៖

- អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

អនុញ្ញាតឱ្យលោក–លោកស្រី : ........................................ ភេទ .................... ថ្ងៃខែឆ្នាំកំណើត..........................

ប្រភេទសេវាកម្ម : អាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ (បន្ត)

អាសយដ្ឋានអាជីវកម្ម : ផ្ទះលេខ ........... ផ្លូវលេខ .............. ឃុំ/សង្កាត់.................... ក្រុង/ស្រុក/ខណ្ឌ ....................

នាមករណ៍ : ..................................................................

បណ្ណអនុញ្ញាតសេវាកម្មនេះមានសុពលភាពត្រឹមថ្ងៃទី.................... ខែ.................... ឆ្នាំ....................

មុនផុតកំណត់រយៈពេល១៥ថ្ងៃ អាជីវករត្រូវយកបណ្ណអនុញ្ញាតនេះ មកប្តូរដើម្បីដាក់សុំបន្តអាជីវកម្មនៅឆ្នាំបន្ទាប់។

ថ្ងៃ............................ ខែ............. ឆ្នាំ............................ព.ស. ...........

............................ថ្ងៃទី.............ខែ................ ឆ្នាំ..............

**អភិបាល**..............................

<u>បញ្ជាក់</u>៖ បណ្ណអនុញ្ញាតនេះត្រូវដាក់តាំង ឬ ព្យួរនៅកន្លែងទទួលភ្ញៀវ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល** ……………………………….

**លេខ** ……………………….. ថ្ងៃ……………………… ខែ…………. ឆ្នាំ……………………..ព.ស. ……….

……………………….ថ្ងៃទី…………ខែ…………….. ឆ្នាំ…………..

## លិខិតអញ្ជើញ
## លោក លោកស្រី ម្ចាស់អាជីវកម្ម

……………………………………………………………………………

**កម្មវត្ថុ** ៖ ស្តីពីការបំពេញកាតព្វកិច្ចបង់កម្រៃអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍

**យោង** ៖ – អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

– ប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ …………………… សូមអញ្ជើញលោក លោកស្រីម្ចាស់អាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ ដែលមានអាសយដ្ឋានផ្ទះលេខ ………. ផ្លូវ ……………… ឃុំ/សង្កាត់ ……………… ក្រុង/ស្រុក/ខណ្ឌ ……………… រាជធានី/ខេត្ត ……………. មកកាន់ការិយាល័យច្រកចេញចូលតែមួយ ដើម្បីបំពេញកាតព្វកិច្ចបង់កម្រៃអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ នៅរៀងរាល់ម៉ោងធ្វើការក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតនេះ។

ជាមួយគ្នានេះ រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ………………… សូមជម្រាបជូនលោក លោកស្រីម្ចាស់អាជីវកម្មជ្រាបថា ការខកខានមិនបានបំពេញកាតព្វកិច្ចដូចដែលបានបញ្ញត្តក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ……………… នឹងចាត់វិធានការផ្អាកអាជីវកម្មជាបណ្តោះអាសន្នស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ………………………. សង្ឃឹមនិងជឿជាក់ថា លោក លោកស្រីម្ចាស់អាជីវកម្មលើទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ នឹងអញ្ជើញមកតាមពេលវេលាកំណត់កុំបីខកខាន។

សូមលោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**អភិបាល**……………………..

ចម្លងជូន៖
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល** ……………………………………
**លេខ** ……………………………

ថ្ងៃ………………………… ខែ…………… ឆ្នាំ………………………ព.ស. …………
…………………………ថ្ងៃទី…………… ខែ……………… ឆ្នាំ……………

**ជម្រាបមក**
**លោក លោកស្រី ម្ចាស់អាជីវកម្ម**
………………………………………………………………………………………

**កម្មវត្ថុ** ៖ ស្តីពីការផ្អាកជាបណ្តោះអាសន្នការប្រកបអាជីវកម្មករណីល្មើសនឹងកាតព្វកិច្ច

**យោង** ៖ – ប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
– លិខិតអញ្ជើញលេខ……………… ចុះថ្ងៃទី…………… ខែ……………… ឆ្នាំ………………… ស្តីពីការបំពេញកាតព្វកិច្ចបង់កម្រៃអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបលោក លោកស្រីម្ចាស់អាជីវកម្ម ………………………………… ដែលមានអាសយដ្ឋាន ផ្ទះលេខ ………… ផ្លូវ ……………… ឃុំ/សង្កាត់ ………………… ក្រុង/ស្រុក/ខណ្ឌ ………………… រាជធានី/ខេត្ត ……………… ជ្រាបថា៖ រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ………………………………… បានពិនិត្យឃើញលោក លោកស្រីម្ចាស់អាជីវកម្មមិនសហការជាមួយក្រុមការងាររបស់ការិយាល័យច្រកចេញចូលតែមួយ ដើម្បីបំពេញកាតព្វកិច្ចបង់កម្រៃអាជីវកម្មទីតាំងផលិតនិងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍តាមបញ្ញត្តិច្បាប់ដែលមានជាធរមាន ដូច្នេះរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ សូមផ្អាកនូវអាជីវកម្មនេះជាបណ្តោះអាសន្នចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីម្ចាស់អាជីវកម្ម ជ្រាបនិងអនុវត្តតាមខ្លឹមសារខាងលើតាមការគួរ។

សូម លោក លោកស្រីម្ចាស់អាជីវកម្ម ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**អភិបាល**…………………………

ចម្លងជូន៖
- អធិការដ្ឋានក្រុង ស្រុក ខណ្ឌ
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត
"ដើម្បីសហការ"